# អដ្ឋកថា គុត្តិលជាតក

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា សត្តតន្តិំ សុមធុរំ ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ក្នុងកាលនោះ ភិក្ខុទាំងឡាយពោលនឹងទេវទត្តថា នែអាវុសោទេវទត្ត ព្រះសម្មាសម្ពុទ្ធជាអាចារ្យរបស់លោក លោកអាស្រ័យព្រះសម្មាសម្ពុទ្ធ រៀនព្រះត្រៃបិដក ញុំាងឈាន ៤ ឲ្យកើតឡើង ការដែលធ្វើខ្លួនឲ្យជាសត្រូវដល់អាចារ្យមិនសមគួរឡើយ ។

ទេវទត្តពោលថា នែអាវុសោទាំងឡាយ ព្រះសមណគោតមជាអាចារ្យរបស់ខ្ញុំឬ ព្រះត្រៃបិដកខ្ញុំរៀនដោយកម្លាំងខ្លួនឯង មិនមែនឬ ឈានទាំង ៤ ខ្ញុំក៏ធ្វើឲ្យកើតដោយកម្លាំងរបស់ខ្លួនទាំងអស់ មិនមែនឬ ។ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តអាស្រ័យព្រះសម្មាសម្ពុទ្ធជាអាចារ្យហើយ ត្រឡប់ជាសត្រូវនឹងព្រះអង្គ បានដល់នូវសេចក្តីវិនាសហើយ ។ ព្រះបរមសាស្តា ស្តេចយាងមកកាន់រោងធម្មសភា ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ។ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកថា

ឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែន បដិសេធអាចារ្យ ជាសត្រូវចំពោះតថាគត ហើយដល់នូវសេចក្ដីវិនាស តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ដល់នូវសេចក្ដី វិនាសដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរ ពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលអ្នកចម្រៀង ។ មាតា បិតាដាក់ឈ្មោះឲ្យថា គុត្តិលកុមារ ។ គុត្តិលកុមារនោះ លុះចម្រើនវ័យ ហើយ សម្រេចសិល្បៈផ្នែកខាងចម្រៀង បានជាអ្នកច្រៀងដ៏កំពូលក្នុង ជម្ពូទ្វីបទាំងមូលឈ្មោះថា គុត្តិលគន្ធព្វ ។ កុមារនោះ មិនមានភរិយា ចិញ្ចឹមមាតាបិតាដែលងងឹតភ្នែក ។ ក្នុងកាលនោះ ពួកឈ្មួញអ្នកនគរ ពារាណសីទៅជួញឯក្រុងឧជ្ជេនី កាលគេប្រកាសថា មានមហោស្រព ទើបរៃអង្គាសគ្នារកផ្កាឈើ គ្រឿងក្រអូប គ្រឿងលាប និងគ្រឿងបរិភោគ ជាដើមយ៉ាងច្រើន ប្រជុំគ្នានៅក្នុងទីលានកីឡា ឲ្យថ្លៃឈ្នួលហើយពោល ថា អ្នកទាំងឡាយ ចូរនាំអ្នកចម្រៀងម្នាក់មកចុះ ។

ក្នុងសម័យនោះ ក្នុងក្រុងឧជ្ជេនីមានអ្នកចម្រៀងដ៏ល្បីម្នាក់ ឈ្មោះ មុសិលៈ ។ ពួកឈ្មួញក៏យកបុរសនោះមក ឲ្យសម្ដែងនិងច្រៀងឲ្យខ្លួន ស្ដាប់ ។ មុសិលៈនោះមុននឹងដេញពិណ ក៏ដំឡើងខ្សែសំឡេងឯក ហើយទើបដេញ ការដេញរបស់មុសិលៈនោះ បានប្រាកដដូចសំឡេង

អេះកន្ទេលផែនដល់ពួកឈ្នួញទាំងនោះ ព្រោះពួកឈ្នួញទាំងនោះជាអ្នកធ្លាប់ត្រចៀកក្នុងការស្ដាប់សំឡេងពិណរបស់គុត្តិលគន្ធព្វ ទើបមិនបានសម្ដែងការពេញចិត្តសូម្បីតែម្នាក់ ។ មុសិលៈនោះ កាលពួកឈ្នួញទាំងនោះ មិនសម្ដែងអាការពេញចិត្តសូម្បីតែម្នាក់ ក៏គិតថា ប្រហែលជាអញដេញពិណតឹងពេកទេដឹង ទើបបន្ថយសំឡេងចុះមកពាក់កណ្ដាលដេញដោយសំឡេងពាក់កណ្ដាល ឈ្នួញទាំងនោះក៏នៅតែមិនយកចិត្តទុកដាក់នឹងសំឡេងពិណនោះ ។ ពេលនោះ មុសិលៈនោះគិតថា ឈ្នួញទាំងនេះគង់មិនដឹងអ្វី ទើបក្លែងធ្វើជាមិនដឹងរឿងខ្លួនឯង ដេញពិណដោយខ្សែធូរៗ ពួកឈ្នួញក៏មិនបានថាអ្វី ។ មុសិលៈនោះក៏ពោលនឹងឈ្នួញទាំងនោះថា នៃឈ្នួញដ៏ចម្រើន កាលខ្ញុំដេញពិណពួកលោកមិនពេញចិត្តឬ ?

ឈ្នួញទាំងនោះពោលថា តើអ្នកដេញពិណអ្វី ពួកយើងមិនបានយល់ថា អ្នកដំឡើងសំឡេងពិណដេញទេ ។

មុសិលៈសួរថា តើពួកលោកស្គាល់អាចារ្យដែលពូកែជាងខ្ញុំ ឬក៏មិនត្រេកអរ ព្រោះខ្លួនមិនចេះស្ដាប់ ?

ឈ្នួញទាំងនោះពោលថា ពួកយើងធ្លាប់ស្ដាប់សំឡេងពិណរបស់គុត្តិលគន្ធព្វឯនគរពារាណសី សំឡេងពិណរបស់គាត់ គេស្ដាប់ទៅដូចសំឡេងស្ត្រីបំពេរកូន ។

មុសិលៈពោលថា បើដូច្នោះ ចូរលោកយកប្រាក់របស់លោកទៅវិញចុះ ខ្ញុំមិនត្រូវការទេ ប៉ុន្តែកាលលោកត្រឡប់ទៅកាន់នគរពារាណសី ជួយនាំខ្ញុំទៅផង ។

ពួកឈ្មួញពោលថា ប្រពៃហើយ ពួកខ្ញុំយល់ព្រម ។ ពេលត្រឡប់ទៅវិញ បាននាំមុសិលៈនោះទៅកាន់នគរពារាណសី ហើយប្រាប់ថា នេះគឺលំនៅរបស់គុត្តិលគន្ធព្វ ហើយក៏ហួសទៅកាន់ផ្ទះរបស់ខ្លួន ។ មុសិលៈនោះចូលទៅក្នុងផ្ទះរបស់ព្រះបរមពោធិសត្វ ឃើញពិណរបស់ព្រះបរមពោធិសត្វ ក៏ចាប់យកមកដេញ ។ ពេលនោះ មាតាបិតារបស់ព្រះមហាសត្វមើលមិនឃើញមុសិលៈព្រោះភ្នែកងងឹត គិតថា ប្រហែលជាកណ្ដុរមកកាត់ពិណហើយមើលទៅ ទើបពោលថា កណ្ដុរកាត់ខ្សែពិណ ។ មុសិលៈក៏ដាក់ពិណចុះ ហើយថ្វាយបង្គំមាតាបិតារបស់ព្រះមហាសត្វ ។

មាតាបិតារបស់ព្រះបរមពោធិសត្វសួរថា អ្នកមកអំពីណា?

មុសិលៈនោះឆ្លើយថា ខ្ញុំមកអំពីក្រុងឧជ្ជេនីដើម្បីសូមរៀនសិល្បៈក្នុងសម្នាក់អាចារ្យ ។

មាតាបិតារបស់ព្រះបរមពោធិសត្វទទួលថា ល្អហើយ ។

មុសិលៈនោះសួរថា លោកអាចារ្យទៅណា ។ កាលបានស្ដាប់ថា មិននៅទេ ប៉ុន្តែថ្ងៃនេះត្រឡប់មកវិញហើយ ទើបអង្គុយនៅទីនោះ ។

កាលព្រះពោធិសត្វត្រឡប់មក បានទទួលបដិសណ្ឋារៈហើយ ក៏ប្រាប់ហេតុដែលខ្លួនមក ។ ចំណែកព្រះបរមពោធិសត្វចេះវិជ្ជាទាយលក្ខណៈមនុស្ស ទើបដឹងថា មុសិលៈនេះជាអសប្បុរស ក៏បដិសេធថា នែអ្នកដ៏ចម្រើន អ្នកទៅចុះ សិល្បៈមិនសម្រេចដល់អ្នកទេ ។

មុសិលៈចាប់ជើងមាតាបិតារបស់ព្រះពោធិសត្វព្របាច់ថ្ពមៗ ឲ្យអាណិតខ្លួន ហើយអង្វរថា សូមលោកទាំងពីរជួយឲ្យលោកអាចារ្យចែកសិល្បៈឲ្យខ្ញុំផងចុះ ។

ព្រះពោធិសត្វត្រូវមាតាបិតាអង្វររឿយៗ ក៏មិនអាចជំទាស់បាន ទើបព្រមបង្រៀនសិល្បៈ ។ មុសិលៈនោះទៅព្រះរាជនិវេសន៍ជាមួយនឹងព្រះបរមពោធិសត្វ ។ ព្រះរាជាទតឃើញក៏ត្រាស់សួរថា បុរសនេះជាអ្នកណា លោកអាចារ្យ ?

ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រមហារាជ បុរសនេះជាអន្តេវាសិករបស់ទូលបង្គំ ។ មុសិលៈក៏បានស្និទ្ធស្នាលជាមួយនឹងព្រះរាជាដោយលំដាប់ ។ ឯព្រះបរមពោធិសត្វមិនបានបិទបាំងលាក់លៀមវិជ្ជា ឲ្យមុសិលៈនោះសិក្សាតាមបែបដែលខ្លួនចេះមករហូតចប់ ហើយពោលថា នែអ្នកដ៏ចម្រើន អ្នករៀនសិល្បៈចប់ហើយ ។ មុសិលៈគិតថា សិល្បៈអញរៀនចប់ហើយ ទាំងនគរពារាណសីនេះ ក៏ជានគរធំជាងគេនៅក្នុងជម្ពូទ្វីប ប្រសិនបើអាចារ្យរបស់អញចាស់ អញគួរនៅក្នុងនគរ

៣ភាណសីនេះឯង ។ មុសិលៈប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំនឹងទទួលរាជការ ។

ព្រះបរមពោធិសត្វពោលថា ប្រពៃហើយ យើងនឹងក្រាបទូលព្រះរាជា ហើយនាំមុសិលនោះទៅគាល់ព្រះរាជា រួចក្រាបទូលថា បពិត្រមហារាជ អន្តេវាសិករបស់ទូលបង្គំចង់ទទួលរាជការបម្រើព្រះអង្គ សូមទ្រង់ពិចារណាបៀវត្សឲ្យគេ ។ កាលព្រះរាជាប្រាប់ថា បុរសនោះនឹងបានពាក់កណ្តាលអំពីបៀវត្សដែលអ្នកបាន ទើបប្រាប់រឿងនោះដល់មុសិលៈ ។

មុសិលៈពោលថា កាលខ្ញុំបានបៀវត្សស្មើនឹងលោក ទើបខ្ញុំទទួលរាជការ កាលមិនបានស្មើនឹងមិនទទួល ។

ព្រះពោធិសត្វសួរថា ព្រោះហេតុអ្វី ?

មុសិលៈពោលថា ខ្ញុំចេះសិល្បៈដែលលោកចេះទាំងអស់ មិនមែនឬ?

ព្រះពោធិសត្វពោលថា ត្រូវហើយ អ្នកចេះទាំងអស់ ។

មុសិលៈពោលថា បើដូច្នោះ ព្រោះហេតុអ្វីទើបព្រះរាជាព្រះរាជទានបៀវត្សដល់ខ្ញុំតែពាក់កណ្តាល ។ ព្រះពោធិសត្វក៏ក្រាបទូលដល់ព្រះរាជា ។

ព្រះរាជាត្រាស់ថា ប្រសិនបើអន្តេវាសិករបស់អ្នកអាចសម្តែង

សិល្បៈស្មើនឹងអ្នក ក៏នឹងបានស្មើគ្នា ។ ព្រះពោធិសត្វស្តាប់ឮដូច្នោះ ហើយក៏ប្រាប់មុសិលៈ កាលមុសិលៈនោះពោលថា ប្រពៃហើយខ្ញុំនឹងសម្តែង ទើបក្រាបទូលព្រះរាជា ។

ព្រះរាជាត្រាស់ថា ប្រពៃហើយ ចូរសម្តែងចុះ តើអ្នកនឹងសម្តែងប្រឡងប្រណាំងក្នុងថ្ងៃណា ?

ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទូលបង្គំនឹងសម្តែងប្រឡងប្រណាំងក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះទៅ ។

ព្រះរាជាបានឲ្យហៅមុសិលៈមក ហើយត្រាស់សួរថា បានឮថាអ្នកនឹងធ្វើការប្រឡងប្រណាំងជាមួយនឹងអាចារ្យឬ ?

មុសិលៈក្រាបទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។

សូម្បីព្រះរាជាទ្រង់ហាមឃាត់ថា ការប្រឡងប្រណាំងជាមួយនឹងអាចារ្យមិនសមគួរឡើយ មុសិលៈនោះ ក៏នៅតែក្រាបទូលថា ណ្ហើយចុះ ព្រះសម្មតិទេព ទុកឲ្យទូលបង្គំប្រឡងជាមួយនឹងអាចារ្យក្នុងថ្ងៃទី ៧ ចុះ នឹងបានដឹងថា អ្នកណាឈ្នះ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ ប្រពៃហើយ ហើយទ្រង់បញ្ជាឲ្យវាយស្គរប្រកាសថា ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ អាចារ្យនិងសិស្ស នឹងសម្តែងសិល្បៈប្រឡងប្រណាំងគ្នានៅត្រង់ខ្លោងទ្វារព្រះរាជវាំង អ្នកនគរចូរមកមើលការប្រឡងប្រណាំងគ្នាចុះ ។ ព្រះមហាសត្វគិតថា មុសិលៈ

នេះ នៅកំលោះមានកម្លាំងខ្លាំង ចំណែកអញចាស់ថយកម្លាំងហើយ ធម្មតាកិរិយារបស់មនុស្សចាស់រមែងមិនស្លាហាប់ ម្យ៉ាងទៀត កាលកូនសិស្សចាញ់ក៏មិនប្លែកអ្វី តែបើកូនសិស្សឈ្នះ អញចូលទៅស្លាប់ក្នុងព្រៃប្រសើរជាង ។ ព្រះពោធិសត្វចូលទៅក្នុងព្រៃ ហើយក៏ត្រឡប់មកវិញ ព្រោះខ្លាចស្លាប់ ហើយត្រឡប់ទៅព្រៃវិញទៀត ព្រោះខ្លាចខ្មាសគេ កាលព្រះមហាបុរសត្រឡប់ទៅត្រឡប់មកយ៉ាងនេះ ថ្ងៃក៏កន្លងទៅបាន ៦ ថ្ងៃ ស្មៅង៉ាប់រាបក្លាយជាស្នាមផ្លូវទៅហើយ ។ ពេលនោះ ភពរបស់សក្កទេវរាជក៏សម្ដែងអាការក្ដៅ សក្កទេវរាជពិចារណាមើលក៏បានដឹងហេតុការណ៍នោះ ទើបត្រិះរិះថា គុត្តិលគន្ធព្វបានទទួលទុក្ខធំក្នុងព្រៃ ព្រោះខ្លាចអន្តេវាសិក អញគួរជាទីពឹងរបស់គុត្តិលៈនោះ ទើបប្រញាប់យាងទៅឈរខាងមុខហើយត្រាស់សួរថា នែអាចារ្យ អ្នកចូលព្រៃធ្វើអ្វី?

ព្រះបរមពោធិសត្វសួរថា អ្នកជាអ្នកណា?

សក្កទេវរាជត្រាស់ថា ខ្ញុំជាសក្កទេវរាជ ។

ពេលនោះ ព្រះបរមពោធិសត្វក៏ទូលសក្កទេវរាជថា បពិត្រទេវរាជ ខ្ញុំចូលព្រៃយ៉ាងនេះ ក៏ព្រោះខ្លាចចាញ់អន្តេវាសិក ហើយពោលគាថាទី ១ ថា

សត្តតន្តឹ សុមធុរំ រាមណេយ្យំ អវាចយឹ
សោ មំ រង្គម្ហិ អវ្ហេតិ សរណំ មេ ហោហិ កោសិយ ។

បពិត្រព្រះឥន្ទ្រកោសិយ ខ្ញុំបាន ( ញ៉ាំងសិស្សឈ្មោះមុសិលៈ) ឲ្យរៀននូវពិណមានខ្សែ ៧ មានសំឡេងពីរោះ ជាទីរីករាយនៃចិត្ត ( ឥឡូវនេះ ) សិស្សឈ្មោះមុសិលៈនោះ ហៅខ្ញុំក្នុងកណ្ដាលរង្គមណ្ឌល ( កន្លែងរាំ ) សូមព្រះអង្គជាទីពឹងនៃខ្ញុំ ។

សក្កទេវរាជស្ដាប់ពាក្យរបស់ព្រះបរមពោធិសត្វហើយត្រាស់ថា កុំខ្លាចឡើយ ខ្ញុំនឹងជួយគាំទ្រការពារអ្នក ហើយពោលគាថាទី ២ ថា

អហំ តំ សរណំ សម្ម អហមាចរិយបូជកោ
ន តំ ជយិស្សតិ សិស្សោ សិស្សមាចរិយ ជេស្សសិ ។

ម្នាលសម្លាញ់ ខ្ញុំនឹងជាទីពឹងរបស់អ្នក ខ្ញុំជាអ្នកបូជានូវអាចារ្យ សិស្សនឹងមិនឈ្នះអ្នក បពិត្រអាចារ្យ អ្នកនឹងឈ្នះនូវសិស្សវិញ ។

សក្កទេវរាជត្រាស់ថា កាលអ្នកដេញពិណ ចូរអ្នកផ្ដាច់ខ្សែមួយ ដេញខ្សែ ៦ សំឡេងពិណរបស់អ្នកនឹងដូចដើម សូម្បីមុសិលៈ ក៏នឹងផ្ដាច់ខ្សែពិណដែរ ប៉ុន្តែសំឡេងពិណរបស់មុសិលៈនោះនឹងមិនដូចដើម ពេលនោះ បុរសនោះនឹងដល់នូវការបរាជ័យ លុះដឹងថា បុរសនោះដល់នូវការបរាជ័យហើយ អ្នកគប្បីផ្ដាច់ខ្សែទី ២ ខ្សែទី ៣ ខ្សែទី ៤ ខ្សែទី ៥ ខ្សែទី ៦ ខ្សែទី ៧ ដេញតែដងពិណទទេ សំឡេងនឹងចេញអំពីកំណាត់ខ្សែពិណដែលផ្ដាច់ចោលនោះ លាន់ឮទូទៅពេញនគរពារាណសីទាំង ១២ យោជន៍ ។ សក្កទេវរាជត្រាស់ដូច្នេះហើយ ក៏ប្រទានចំពៀន

៣ វង់ដល់ព្រះពោធិសត្វ ហើយត្រាស់ថា កាលសំឡេងពិណរបស់អ្នកលាន់ឮទូទាំងនគរហើយ អ្នកចូរបោះចំញៀន ១ វង់អំពីចំនួននេះ ទៅក្នុងអាកាស ពេលនោះ ស្រីទេពអប្សរ ៣០០ នឹងចុះមករាំខាងមុខអ្នក ក្នុងពេលដែលស្រីទេពអប្សរកំពុងរាំនោះ អ្នកគប្បីបោះចំញៀនទី ២ ទៅទៀត ស្រីទេពអប្សរ ៣០០ ទៀត នឹងចុះមករាំខាងមុខពិណរបស់អ្នកទៀត បន្ទាប់អំពីនោះ អ្នកគប្បីបោះចំញៀនទី ៣ ទៅទៀត ពេលនោះស្រីទេពអប្សរ ៣០០ ទៀតនឹងចុះមករាំលើកន្ទ្រង់រាំ សូម្បីខ្ញុំក៏នឹងទៅរកអ្នកដែរ ដូច្នេះ ចូរអ្នកទៅចុះ កុំខ្លាចឡើយ ។

លុះព្រឹកឡើង ព្រះបរមពោធិសត្វក៏ត្រឡប់មកផ្ទះវិញ ។ ពួកអ្នកនគរធ្វើមណ្ឌបនៅជិតខ្លោងទ្វារព្រះរាជវាំង តាក់តែងទីប្រថាប់សម្រាប់ព្រះរាជា ។ ព្រះរាជាស្ដេចចុះអំពីប្រាសាទហើយទ្រង់គង់លើបល្ល័ង្កនៅក្នុងរង្គមណ្ឌបដែលតាក់តែងហើយ ។ ស្ត្រីដែលប្រដាប់តាក់តែងហើយ ១ ម៉ឺន និងអាមាត្យ ព្រាហ្មណ៍ អ្នកដែនជាដើម មកគាល់ណែនណាន់តាន់តាប់ ។ អ្នកនគរក៏មកប្រជុំគ្នា ក្នុងលានព្រះរាជវាំង យករថតម្រួតលើរថ គ្រែតម្រួតលើគ្រែ ។ ឯព្រះបរមពោធិសត្វងូតទឹកជម្រះកាយហើយ បរិភោគអាហារដែលមានរសប្រណីតផ្សេងៗ ហើយកាន់ពិណទៅអង្គុយលើអាសនៈសម្រាប់ខ្លួន ។ សក្កទេវរាជមកឋិតនៅលើអាកាសដោយមិនប្រាកដកាយ ព្រះបរមពោធិសត្វតែម្នាក់ប៉ុណ្ណោះដែលឃើញ

សក្កទេវរាជ ។ ចំណែកមុសិលៈក៏មកអង្គុយលើអាសនៈរបស់ខ្លួនដែរ ។ មហាជនចោមរោមហើយ ។ ជនទាំងពីរក៏ដេញពិណ តាំងអំពីដើមស្មើគ្នា ។ មហាជនស្រែកហ៊ោត្រេកអររីករាយដោយការដេញពិណនៃអ្នកទាំងពីរ សក្កទេវរាជឋិតនៅលើអាកាស ប្រាប់ឲ្យឮតែព្រះពោធិសត្វម្នាក់ប៉ុណ្ណោះថា ចូរអ្នកផ្តាច់ខ្សែពិណទី ១ ចេញ ។ ព្រះពោធិសត្វផ្តាច់ខ្សែពិណទី ១ចោល សូម្បីផ្តាច់ខ្សែទី ១ ចេញហើយក៏ដោយ សំឡេងក៏នៅតែឮចេញអំពីកំណួចដែលដាច់ហើយនោះ បីដូចជាសំឡេងពិណរបស់ទេពគន្ធព្វដូច្នោះ ឯមុសិលៈក៏ផ្តាច់ខ្សែពិណខ្លះចោលដែរ ប៉ុន្តែសំឡេងមិនឮចេញមក ។ ព្រះពោធិសត្វបានផ្តាច់ខ្សែទី ២ ទី ៣ ទី ៤ ទី ៥ ទី ៦ ទី ៧ ។ កាលដេញតែដងពិណទទេ សំឡេងបានលាន់ឮពេញនគរ សម្រែកហ៊ោ និងទង់បក់បោកជាច្រើនបានប្រព្រឹត្តទៅហើយ ។ ព្រះពោធិសត្វបានបោះចំនៀនវង់ទី ១ ទៅក្នុងអាកាស ក្នុងពេលនោះស្រីទេពអប្សរ ៣០០ បានចុះមករាំ កាលបោះវង់ទី ២ និងទី ៣ ទៅទៀត មានទេពអប្សរ ៩០០ បានចុះមករាំតាមន័យដូចពោលហើយនោះ ។ កាលព្រះរាជាឲ្យសញ្ញាដល់មហាជន មហាជនក៏នាំគ្នាក្រោកឡើងគំរាមដល់មុសិលៈថា អ្នកប្រឡងប្រណាំងនឹងអាចារ្យ ព្យាយាមធ្វើអាការស្មើនឹងអាចារ្យ អ្នកមិនស្គាល់ប្រមាណខ្លួន គប់វាយដោយដុំដី ដុំថ្មនិងដំបងជាដើម តាមដែលចាប់យកមកបាន ឲ្យដល់នូវសេចក្តី

ស្លាប់ ហើយចាប់ជើងអូសយកទៅចោលនៅលើគំនរសំរាម ។ ព្រះរាជាមានព្រះទ័យត្រេកអរ ព្រះរាជទានទ្រព្យជាច្រើនដល់ព្រះពោធិសត្វ ដូចភ្លៀងព្រិលធ្លាក់ចុះមកដូច្នោះ ។ អ្នកនគរក៏យ៉ាងនោះដែរ ។

សក្កទេវរាជទ្រង់ធ្វើបដិសណ្ឋារៈនឹងព្រះពោធិសត្វថា នែបណ្ឌិត ខ្ញុំនឹងឲ្យមាតលិសារថីយករថទឹមដោយសេះអាជានេយ្យ ១ ពាន់ មកទទួលអ្នកខាងក្រោយ អ្នកគប្បីឡើងកាន់វេជយន្តរថដែលទឹមដោយសេះ ១ ពាន់ទៅកាន់ទេវលោកចុះ លុះត្រាស់ដូច្នេះហើយ ទ្រង់ក៏ត្រឡប់ទៅកាន់ទេវលោកវិញ ។

គ្រានោះ ទេពធីតាទាំងឡាយក៏សួរសក្កទេវរាជដែលយាងមកដល់ហើយគង់លើបណ្ឌុកម្ពលសិលាសនៈថា បពិត្រទេវរាជ ព្រះអង្គយាងទៅណា ទើបតែមក?

សក្កទេវរាជក៏ត្រាស់ប្រាប់ហេតុការណ៍នោះ ឲ្យពួកទេពធីតាស្តាប់ដោយពិស្តារហើយពណ៌នាសីលនិងគុណរបស់ព្រះពោធិសត្វ ។ ពួកទេពធីតាក្រាបទូលថា បពិត្រមហារាជ សូម្បីពួកខ្ញុំម្ចាស់ ក៏ប្រាថ្នាឃើញអាចារ្យនោះដែរ ។

សក្កទេវរាជហៅមាតលិទេវបុត្តមកត្រាស់ថា នែបា ទេពអប្សរ ចង់ឃើញគុត្តិលគន្ធព្វ អ្នកចូរទៅ ឲ្យគុត្តិលគន្ធព្វនោះអង្គុយលើវេជយន្តរថហើយនាំមកទីនេះចុះ ។ មាតលិទេវបុត្តទទួលទេវឱង្ការហើយ ទៅនាំ

ព្រះពោធិសត្វមក ។

សក្កទេវរាជទ្រង់រីករាយជាមួយនឹងព្រះពោធិសត្វ ហើយត្រាស់ថា ទេវកញ្ញា កិរ តេ អាចរិយ គន្ធព្វំ សោតុកាមា នៃអាចារ្យ ពួកទេពកញ្ញាប្រាថ្នានឹងស្តាប់ការលេងភ្លេងរបស់អ្នក ។

ព្រះពោធិសត្វក្រាបទូលថា មយំ មហារាជ គន្ធព្វា នាម សិប្បំ និស្សាយ ជីវាម, មូលំ លភន្តា វាទេយ្យាម បពិត្រមហារាជ ពួកខ្ញុំជាគន្ធព្វចិញ្ចឹមជីវិតអាស្រ័យសិល្បៈ កាលបានថ្លៃឈ្នួល ទើបលេង ។

សក្កទេវរាជត្រាស់ថា ចូរលេងចុះ ខ្ញុំនឹងឲ្យថ្លៃឈ្នួល ។

ព្រះពោធិសត្វក្រាបទូលថា ខ្ញុំមិនត្រូវការថ្លៃឈ្នួលយ៉ាងដទៃទេ សូមឲ្យតែស្រីទេពអប្សរទាំងនេះ ប្រាប់កល្យាណកម្មរបស់ខ្លួនដល់ខ្ញុំចុះ បើយ៉ាងនេះ ខ្ញុំនឹងលេងភ្លេងឲ្យស្តាប់ ។

គ្រានោះ ទេពធីតាទាំងនោះ បានពោលនឹងព្រះពោធិសត្វថា ពួកខ្ញុំនឹងប្រាប់កល្យាណកម្មរបស់ពួកខ្ញុំជាខាងក្រោយ សូមលោកអាចារ្យលេងភ្លេងមុនចុះ ។ ព្រះពោធិសត្វលេងភ្លេងឲ្យពួកទេវតាស្តាប់អស់ ៧ ថ្ងៃ សំឡេងនោះ ពីរោះលាន់រំពងជាងតិណទិព្វទៅទៀត ។ លុះគ្រប់ ៧ ថ្ងៃ ព្រះមហាសត្វក៏ផ្តើមសួរទេពធីតាទាំងឡាយអំពីកល្យាណកម្ម ។

ទេពធីតាមួយអង្គ បានប្រគេនសំពត់យ៉ាងល្អដល់ភិក្ខុមួយអង្គ

ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ទើបបានមកកើតជាបាទបរិចារិកា របស់សក្កទេវរាជ មានស្រីទេពអប្សរ ១ ពាន់ជាបរិវារ ។ ព្រះពោធិសត្វក៏សួរទេពកញ្ញាដែលទ្រទ្រង់ពស្ត្រាភរណៈដ៏ប្រសើរថា កាលពីជាតិមុននាងបានធ្វើកម្មអ្វីទុក ?

ការដែលព្រះពោធិសត្វសួរនឹងទេពកញ្ញាដែលធ្វើយនោះ បានមានមកហើយក្នុងវិមានវត្ថុនោះឯង ។ សេចក្តីក្នុងវិមានវត្ថុនោះ ព្រះពោធិសត្វសួរថា

អភិក្កន្តេន វណ្ណេន     យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា     ឱសធី វិយ តារកា
កេន តេ តាទិសោ វណ្ណោ     កេន តេ ឥធមិជ្ឈតិ
ឧប្បជ្ជន្តិ ច តេ ភោគា     យេ កេចិ មនសោ បិយា

បុច្ឆាមិ តំ ទេវិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្វទិសា បភាសតិ ។

ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក សម្បុររបស់នាងបែបនោះ តើសម្រេចដោយបុណ្យដូចម្តេច ផលសម្រេចដល់នាងក្នុងទីនេះផង ភោគៈ

ទាំងឡាយ ណាទីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើង ដល់នាងផង តើដោយហេតុដូចម្តេច

ម្នាលទេវតា មានអានុភាពច្រើន ខ្ញុំសួមសួរនាង នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច នាងមានអានុភាពរុងរឿង យ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យដូចម្តេច ។

ទេពធីតានោះ ឆ្លើយថា

វត្ថុត្តមទាយិកា នារី
បវរា ហោតិ នរេសុ នារីសុ
ឯវំ បិយរូបទាយិកា មនាបំ
ទិព្វំ សា លភតេ ឧបេច្ច ឋានំ
តស្សា មេ បស្ស វិមានំ
អច្ឆរា កាមវណ្ណិនីហមស្មិ
អច្ឆរាសហស្សាហំ បវរា
បស្ស បុញ្ញានំ វិបាកំ
តេន មេ តាទិសោ វណ្ណោ ។ បេ ។
វណ្ណោ ច មេ សព្វទិសា បភាសតិ ។

នារីឲ្យនូវសំពត់ដ៏ឧត្តម ជាស្ត្រីប្រសើរជាងជនប្រុសស្រីទាំង

ឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទីស្រឡាញ់ ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើល នូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។ បេ ។ ទាំងសម្បុររបស់ខ្ញុំក៏ភ្លឺច្បាស់សព្វទិស[១] ។

ទេពធីតាមួយអង្គទៀត បានឲ្យនូវផ្កាដ៏ឧត្តមចំពោះភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្តមួយរូប ។ ទេពធីតាមួយអង្គទៀត កាលគេប្រាប់ថា សូមអ្នកទាំងឡាយប្រគេនគ្រឿងក្រអូបសម្រាប់ព្រោះព្រំចេតិយចុះ បានប្រគេនគ្រឿងក្រអូបដ៏ឧត្តម ។ មួយអង្គទៀត បានប្រគេនផ្លែឈើមានរសដ៏ឧត្តម ។ មួយអង្គទៀត បានប្រគេនអាហារមានរសដ៏ឧត្តម ។ មួយអង្គទៀត បានប្រគេនគ្រឿងព្រោះព្រំ មានក្លិនក្រអូបលើស្តូបនៃព្រះមានព្រះភាគទ្រង់ព្រះនាមកស្សបៈ ។ មួយអង្គទៀត បានឃើញនូវពួកភិក្ខុនិងពួកភិក្ខុនី

---

១-បិ. ៥៥ ទំ.៥៩ ។

ដើរទៅកាន់ផ្លូវ បានស្តាប់ធម៌របស់ភិក្ខុនិងភិក្ខុនីទាំងឡាយនោះ ហើយរក្សាឧបោសថអស់មួយថ្ងៃ ។ មួយអង្គទៀត ឈរក្នុងទឹក មានចិត្តជ្រះថ្លាបានប្រគេនទឹកដល់ភិក្ខុ អ្នកធាន់ចង្ក្រាន់ក្នុងទូក ។ មួយអង្គទៀត កាលនៅគ្រប់គ្រងផ្ទះមិនច្រើនទៅដោយសេចក្តីក្រោធ ។ មួយអង្គទៀត មិនមានសេចក្តីច្រណែន បានបម្រើម្តាយក្មេកនិងឪពុកក្មេកដែលកាចផង ទិងច្រើនផង អាក្រក់ផងបែងចំណែកដែលខ្លួនបានចេញ ចែកតាយជាមុន ទើបបរិភោគ ទាំងជាអ្នកមិនប្រមាទក្នុងសីលរបស់ខ្លួន ។ មួយអង្គទៀត ជាទាសីធ្វើការបម្រើជនដទៃ ជាអ្នកមិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងពួង ជាស្ត្រីមិនមានសេចក្តីក្រោធ មិនមើលងាយគេ ជាអ្នកចែករំលែកនូវចំណែករបស់ខ្លួនដល់ជនអ្នកត្រូវការ ទើបបានមកកើតជាបាទ-បរិចារិកានៃសក្កទេវរាជ ។

សេចក្តីទាំងអស់នេះ នៅក្នុងគុត្តិលវិមានវត្ថុ ។ នាងទេពធីតា ៣៧ អង្គ បានធ្វើកម្មណាទុក ទើបបានមកកើតក្នុងទេវលោកទាំងអស់កាលព្រះបរមពោធិសត្វសួរ បានពោលគាថាទាំងឡាយសម្តែងកម្មដែលខ្លួនបានធ្វើទុក ។ ព្រះបរមពោធិសត្វបានស្តាប់ពាក្យនោះហើយពោលថា ជាលាភរបស់ខ្ញុំពិតមែនហ្ន៎ ខ្ញុំបានល្អហើយហ្ន៎ ដំណើរមកទីនេះបានស្តាប់សម្បត្តិដែលបានមកដោយកម្ម សូម្បីមានប្រមាណតិច តាំង

អំពីពេលនេះទៅ ខ្ញុំត្រឡប់ទៅកាន់មនុស្សលោកវិញហើយ ខ្ញុំនឹងធ្វើតែកុសលកម្ម មានទានជាដើមប៉ុណ្ណោះ ហើយបានបន្លឺឧទានដូច្នេះថា

ស្វាគតំ វត មេ អជ្ជ សុប្បភាតំ សុហុដ្ឋិតំ
យំ អទ្ទសំ ទេវតាយោ អច្ឆរា កាមវណ្ណិនិយោ
តាសាហំ ធម្មំ សុត្វាន កាហាមិ កុសលំ ពហុំ
ទានេន សមចរិយាយ សំយមេន ទមេន ច
សាហំ តត្ថ គមិស្សាមិ យត្ថ គន្ត្វា ន សោចរេ ។

ឱហ្ន៎ ដំណើរមកនៃអញក្នុងថ្ងៃនេះ ជាការល្អណាស់តើ ថ្ងៃនេះភ្លឺល្អណាស់ ការក្រោកឡើង អំពីដំណេកល្អណាស់ ព្រោះអញបានឃើញពួកទេវតា ជាស្ត្រីអប្សរ មានសម្បុរជាទីប្រាថ្នា អាត្មាអញនោះ បានស្តាប់ធម៌របស់ពួកទេវតាទាំងនោះ នឹងបានធ្វើកុសលច្រើន ដោយការឲ្យទានផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមផង ដោយការទូន្មានផង អ្នកផង ទៅក្នុងទីណាហើយមិនសោយសោក អាត្មាអញនោះ នឹងទៅក្នុងទីនោះដែរ (១) ។

លុះគ្រប់ ៧ ថ្ងៃ សក្កទេវរាជឲ្យមាតលិទេវសារថីនាំព្រះមហាសត្វ

---

១. បិ. ៥៥ ទំ. ៧០ ។

ដែលអង្គុយលើរថ មកកាន់នគរពារាណសីវិញ ។ ព្រះបរមពោធិសត្វ កាលមកដល់នគរពារាណសីហើយ ក៏តំណាលរឿងនោះប្រាប់ដល់ពួកមនុស្ស មនុស្សទាំងនោះ ក៏ដល់នូវសោមនស្សរាហ៍ក្នុងបុណ្យគ្រប់ៗ គ្នា ។

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា មុសិលៈក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ សក្កទេវរាជ បានមកជាអនុរុទ្ធ ព្រះរាជាបានមកជាអានន្ទ ចំណែកគុត្តិលគន្ធព្វ គឺ **តថាគត** នេះឯង ។

ចប់ អដ្ឋកថា គុត្តិលជាតក ទី ៣ ។